**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និង**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ..០១១...ស.ណ.ក

# សេចក្តីណែនាំរួម

## ស្តីពី

## កិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ក្នុងកិច្ចដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦

យោងតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រសួងមហាផ្ទៃបានដាក់ចេញលិខិតណែនាំជាបន្តបន្ទាប់ដល់អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ និងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ឲ្យបង្កលក្ខណៈងាយស្រួល ព្រមទាំងផ្តល់នូវកិច្ចសហប្រតិបត្តិការដល់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីជាធរមាន សំដៅរួមគ្នាសម្រេចបានលទ្ធផលជាវិជ្ជមាននូវកិច្ចការនានាក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦នេះ។

ទន្ទឹមនឹងកិច្ចការនានាដែលសម្រេចបាននាពេលកន្លងមក នៅមានកិច្ចការសំខាន់ៗមួយចំនួនទៀតដែលត្រូវបន្តចូលរួមអនុវត្តក្នុងកិច្ចដំណើរការរៀបចំការបោះឆ្នោតនេះ។ កិច្ចការទាំងនោះ មានជាអាទិ៍ យុទ្ធនាការឃោសនាបោះឆ្នោត ការដឹកជញ្ជូនសម្ភារបរិក្ខារបម្រើឲ្យការបោះឆ្នោត និងការដឹកជញ្ជូនត្រឡប់មកវិញ ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។

ដើម្បីធានាឲ្យដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ប្រព្រឹត្តទៅប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ពិសេសក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោត និងការបោះឆ្នោត ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមធ្វើការណែនាំដល់អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ កងកម្លាំងមានសមត្ថកិច្ច និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឲ្យយកចិត្តទុកដាក់លើកិច្ចការសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

**១-ការបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយ ក្នុងការចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦**

ដើម្បីបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានដាក់ចេញលិខិតលេខ៧០៥ សជណ ចុះថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨។ ជាពិសេស នៅមុនពេលឃោសនាបោះឆ្នោត រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើការណែនាំដល់អាជ្ញាធរឃុំ សង្កាត់ ដើម្បីសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ក្នុងការធ្វើសកម្មភាពនានាស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦។

**២-ការពង្រឹងកិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់**

ក.ដើម្បីធានាឲ្យមានកិច្ចសហការល្អជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំឲ្យមានកម្មវិធីជួបប្រជុំជាប្រចាំជាមួយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដើម្បីផ្លាស់ប្តូរព័ត៌មានអំពីការងារចំពោះមុខមានដូចជា ការងារសន្តិសុខ ការរៀបចំ និងគ្រប់គ្រងដំណើរការឃោសនាបោះឆ្នោត និងកិច្ចសហប្រតិបត្តិការផ្សេងៗទៀតក្នុងការងារបោះឆ្នោត។

ខ.អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសហការជាមួយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ចាត់ឲ្យមានកិច្ចប្រជុំនៅក្នុង**សប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០១៨** នេះ ដោយមានការចូលរួមពីថ្នាក់ដឹកនាំរាជធានី ខេត្ត មន្ទីរនានាជុំវិញរាជធានី ខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ យន្តការ-រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតរាជធានី ខេត្ត គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ក្នុងរាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលចាំបាច់។

ក្នុងកិច្ចប្រជុំនេះ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជូនអំពីដំណើរការរៀបចំការបោះឆ្នោត ការជ្រើសរើស និងការបណ្តុះបណ្តាលមន្ត្រីបោះឆ្នោត បទបញ្ញា និងនីតិវិធីនៃការឃោសនាបោះឆ្នោត ការផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោត ដើម្បីឲ្យអាជ្ញាធររាជធានី ខេត្ត ផ្សព្វផ្សាយណែនាំបន្តដល់អាជ្ញាធរដែនដី និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងរាជធានី ខេត្តនីមួយៗ អំពីតួនាទី ភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចនានាអំពីផែនការ និងវិធានការសន្តិសុខបោះឆ្នោត ព្រមទាំងវិស័យការងារផ្សេងទៀតនៅក្នុងដំណើរការរៀបចំការបោះឆ្នោត។

គ.រៀងរាល់សប្តាហ៍ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត នឹងចាត់ឲ្យមានកិច្ចប្រជុំមួយ ដោយមានការចូលរួមពីយន្តការ-រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតរាជធានី ខេត្ត គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នពាក់ព័ន្ធនានាក្នុងរាជធានី ខេត្ត ដើម្បីធ្វើការផ្លាស់ប្តូរព័ត៌មាន ធ្វើការពិគ្រោះ និងស្វែងរកដំណោះស្រាយសមស្រប រួមនឹងចាត់វិធានការបង្ការ ទប់ស្កាត់ និងកាត់បន្ថយរាល់បញ្ហាទំនាស់ ឬបាតុភាពអសកម្ម និងបញ្ហានានាទាក់ទងនឹងការបោះឆ្នោត។ ក្នុងកិច្ចប្រជុំនេះ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចាត់តាំងតំណាងដែលជាសមាជិកនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ចូលរួមឲ្យបានជាប្រចាំ។

ឃ.ក្រោយពីគណៈកម្មការរៀបចំការបោះឆ្នោតឃុំ សង្កាត់ ត្រូវបានប្រកាសតែងតាំងរួចហើយ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ឲ្យអនុវត្តការងារស្របតាមបែបបទ និងនីតិវិធីដូចនៅថ្នាក់រាជធានី ខេត្តដែរ ដោយមានការសម្របសម្រួលពីគណៈកម្មការរៀបចំការបោះឆ្នោតរាជធានី ខេត្ត។

**៣-អំពីសកម្មភាពរបស់គណបក្សនយោបាយមុនដំណាក់កាលឃោសនាបោះឆ្នោត និងសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

ក.បន្ថែមលើការណែនាំរបស់ក្រសួងមហាផ្ទៃ ក្នុងលិខិតលេខ២៥៩ សជណ ចុះថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតដល់ការធ្វើសកម្មភាពនយោបាយស្របច្បាប់របស់គណបក្សនយោបាយនានា ដែលមិនមែនជាសកម្មភាពឃោសនាបោះឆ្នោត ដូចជា៖

-ការជួបប្រជុំមន្ត្រីគណបក្សក្នុងទីស្នាក់ការគណបក្សនីមួយៗ ឬនៅលំនៅដ្ឋានឯកជន ឬទីកន្លែងឯកជន ដោយមានការយល់ព្រមពីម្ចាស់ទីលំនៅ ឬទីកន្លែងទាំងនោះ។

-ការលើកស្លាកសញ្ញាគណបក្សនៅទីស្នាក់ការរបស់ខ្លួន ឬលំនៅដ្ឋានឯកជន ឬទីតាំងឯកជន ដោយមានការយល់ព្រមពីម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងទាំងនោះ។

ការជួបប្រជុំ និងការលើកស្លាកគណបក្សក្នុងករណីខាងលើនេះ គណបក្សនយោបាយនីមួយៗ គ្រាន់តែជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់តែប៉ុណ្ណោះ ដោយមិនតម្រូវឲ្យសុំការអនុញ្ញាតជាមុនពីអាជ្ញាធរឡើយ លើកលែងតែការជួបប្រជុំនយោបាយនៅតាមទីសាធារណៈ និងការលើកស្លាកសញ្ញាគណបក្សនៅតាមទីសាធារណៈ ទីប្រជុំជន ឬតាមដងផ្លូវនានា។ ពេលទទួលបានការជូនព័ត៌មានជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយរួចហើយ អាជ្ញាធរឃុំ សង្កាត់ ត្រូវរាយការណ៍ជូនអាជ្ញាធរក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការគាំទ្រ និងសហការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន។ គណបក្សនយោបាយសាមី ឬម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងឯកជន ត្រូវផ្តល់នូវកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រកបដោយការយោគយល់អំពីវិធានការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

-ការជួបប្រជុំនយោបាយ និងការលើកស្លាកគណបក្សនៅទីសាធារណៈ ទីប្រជុំជន ដងផ្លូវនានា។

ចំពោះការជួបប្រជុំនយោបាយ ដែលរៀបចំដោយគណបក្សនយោបាយ ហើយដែលមិនមែនជាសកម្មភាពបាតុកម្ម ក្បួនដង្ហែដែលស្ថិតក្នុងក្របខណ្ឌច្បាប់ដោយឡែក និងការលើកស្លាកសញ្ញាគណបក្សនៅតាមទីសាធារណៈ ទីប្រជុំជន ឬតាមដងផ្លូវនានា ក្រោយកាលបរិច្ឆេទនៃសេចក្តីណែនាំរួមនេះ សាមីគណបក្សនយោបាយត្រូវសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។ ពាក្យសុំជួបប្រជុំនយោបាយ និងលើកស្លាកសញ្ញាគណបក្សនយោបាយដូចករណីខាងលើនេះ ត្រូវដាក់ជូនទៅអាជ្ញាធរឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងតិច ៣(បី)ថ្ងៃ មុនការជួបប្រជុំ ឬការលើកស្លាកសញ្ញា។ អាជ្ញាធរឃុំ សង្កាត់ ត្រូវពិចារណាអំពីសំណើនេះ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន អំពីបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ពិសេសសុវត្ថិភាពចរាចរ សោភ័ណភាព និងអនាម័យសាធារណៈ ហើយត្រូវឆ្លើយតបចំពោះសំណើសុំក្នុងរយៈពេល១(មួយ)ថ្ងៃបន្ទាប់ពីទទួលសំណើ។ ក្នុងករណីអាជ្ញាធរឃុំ សង្កាត់មិនអាចសម្រេចបាន អាជ្ញាធរឃុំ សង្កាត់ត្រូវស្នើសុំយោបល់ពីអាជ្ញាធរក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត រួចហើយអាជ្ញាធរឃុំ សង្កាត់ត្រូវឆ្លើយតបទៅសាមីគណបក្សវិញយ៉ាងតិច ១(មួយ)ថ្ងៃ មុនថ្ងៃជួបប្រជុំ ឬលើកស្លាកសញ្ញា។

ការជួបប្រជុំនយោបាយនៅទីសាធារណៈ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការពិគ្រោះពិភាក្សាជាមួយគណបក្សនយោបាយសាមី អំពីវិធានការចាំបាច់ដែលគណបក្សនយោបាយត្រូវផ្តល់កិច្ចសហការ និងការយោគយល់គ្នាទៅវិញទៅមក អំពីបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងអនាម័យសាធារណៈ។

ខ.បន្ថែមលើសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ក្នុងលិខិតលេខ១៧៥៣ សជណ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កភាពងាយស្រួលបន្ថែមទៀតដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើសកម្មភាពដូចជា ការផ្សព្វផ្សាយ ការចែកចាយឯកសារ ខិតប័ណ្ណរូបភាព ការប្រជុំផ្សព្វផ្សាយ ការចាក់ផ្សាយ និងការសំដែងជាសាធារណៈនានា ដើម្បីធ្វើការអប់រំអ្នកបោះឆ្នោតអំពីដំណើរការបោះឆ្នោត ស្របទៅតាមច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ទាក់ទងនឹងការបោះឆ្នោត។

ការប្រជុំផ្សព្វផ្សាយ ការប្រជុំរៀនសូត្រ ការចាក់ផ្សាយ និងការសំដែងនានានៅកន្លែងឯកជន ឬនៅអគារសាធារណៈ ត្រូវមានការយល់ព្រមពីម្ចាស់ទីកន្លែងឯកជន ឬអ្នកគ្រប់គ្រងអាគារសាធារណៈជាមុន។ ក្នុងករណីនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសាមី គ្រាន់តែជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់ ក្នុងរយៈពេល ៤៨ម៉ោងមុន ដោយមិនតម្រូវឲ្យធ្វើការសុំច្បាប់អនុញ្ញាតជាមុនឡើយ។ ពេលទទួលបានការជូនព័ត៌មានជាលាយលក្ខណ៍អក្សររួចហើយ អាជ្ញាធរឃុំ សង្កាត់ ត្រូវជូនដំណឹងដល់អង្គភាពពាក់ព័ន្ធដើម្បីចាត់ការតាមសមត្ថកិច្ច។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ទីកន្លែងឯកជន និងអ្នកគ្រប់គ្រងអគារសាធារណៈនោះ ត្រូវផ្តល់នូវកិច្ចសហការជាមួយកងកម្លាំងមានសមត្ថកិច្ច ប្រកបដោយការយោគយល់អំពីវិធានការសន្តិសុខសណ្តាប់ធ្នាប់ក្នុងករណីចាំបាច់។

ចំពោះការប្រជុំ ឬការសំដែងនៅទីសាធារណៈ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសាមី ត្រូវស្នើសុំការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។ បែបបទ និងនីតិវិធីនៃការស្នើសុំការអនុញ្ញាតនេះ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុច "**៣ក**" ខាងលើនេះ។

ដោយឡែក ចំពោះការចែកចាយឯកសារ ឬរូបភាពផ្សេងៗសម្រាប់អប់រំអ្នកបោះឆ្នោត សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា អាចធ្វើការចែកចាយជូនអ្នកបោះឆ្នោត ដោយមិនចាំបាច់សុំការអនុញ្ញាត ឬជូនដំណឹងទៅអាជ្ញាធរឡើយ។ ប៉ុន្តែ ក្នុងករណីដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមានបំណង បិទផ្សព្វផ្សាយឯកសារ ឬរូបភាពនោះនៅតាមទីសាធារណៈ ចាំបាច់ត្រូវសុំការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចនៃទីកន្លែងនោះ។

**៤-ការកំណត់តម្រាយថ្លុង ការប្រើប្រាស់ពេទមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ និងសាលសាធារណៈសម្រាប់ការឃោសនាបោះឆ្នោត**

ដើម្បីជួយសម្រួល និងរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងអំឡុងពេលនៃដំណើរការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨ នាពេលខាងមុខនេះ ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមធ្វើការណែនាំដល់អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដូចខាងក្រោម៖

-ត្រូវពិភាក្សា និងឯកភាពគ្នាក្នុងការកំណត់ទីតាំងសាធារណៈសម្រាប់ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ របស់គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជន និងបានទទួលស្គាល់ជាផ្លូវការដោយ គ.ជ.ប។

-ត្រូវធ្វើកាលវិភាគប្រចាំសប្តាហ៍ស្តីពីការកំណត់តាមលំដាប់មុនក្រោយ នៃការប្រើប្រាស់ទីតាំងសាធារណៈ ឬកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គឃ.សប ចំនួន ០១ច្បាប់ និងនៅកន្លែងដែលត្រូវធ្វើការឃោសនាបោះឆ្នោត ចំនួន ០១ច្បាប់។

-ត្រូវសហការសម្របសម្រួល និងរៀបចំតាមលំដាប់លំដោយមុនក្រោយនៃការជូនដំណឹង ស្តីពីការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ដោយត្រូវធ្វើការណែនាំឲ្យគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ។

-ត្រូវចាត់វិធានការទប់ស្កាត់ និងដោះស្រាយចំពោះការឃោសនាបោះឆ្នោតទាំងឡាយណាដែលផ្ទុយនឹងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨។

-ត្រូវសហការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយឲ្យបានល្អ និងត្រឹមត្រូវតាមពេលវេលា និងទីកន្លែងកំណត់ តាមដងផ្លូវ ទីប្រជុំជន និងទីតាំងសាធារណៈ នូវគ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ។

**៥-ការធានាសន្តិសុខបោះឆ្នោត**

អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ និងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវផ្តល់កិច្ចសហការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បី

រក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត មានជាអាទិ៍ ការឃោសនាបោះឆ្នោត ការដឹកជញ្ជូនសម្ភារបរិក្ខារបម្រើឲ្យការបោះឆ្នោត និងការដឹកជញ្ជូនត្រឡប់មកវិញ ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត ស្របតាមផែនការការពារសន្តិសុខ សុវត្ថិភាព ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ដែលបានដាក់ចេញដោយយន្តការ-រចនាសម្ព័ន្ធសន្តិសុខថ្នាក់កណ្តាល។ ទន្ទឹមនេះ ត្រូវយកចិត្តទុកដាក់បន្ថែមលើបញ្ហាមួយចំនួនដូចខាងក្រោម៖

**ក.ថ្នាក់រាជធានី ខេត្ត**

ក្រៅពីការប្រជុំប្រចាំសប្តាហ៍ អាចធ្វើការកោះប្រជុំដោយឡែកតាមការចាំបាច់ និងតាមសភាពការណ៍ជាក់ស្តែងនៃសន្តិសុខនៅតាមរាជធានី ខេត្តនីមួយៗ។ ទន្ទឹមនេះ ត្រូវបាត់ឲ្យមានការផ្លាស់ប្តូរព័ត៌មានជាប្រចាំរវាងយន្តការ-រចនាសម្ព័ន្ធសន្តិសុខរាជធានី ខេត្ត និងគណៈកម្មការរៀបចំការបោះឆ្នោតរាជធានី ខេត្ត ព្រមទាំងកងកម្លាំងមានសមត្ថកិច្ចនានា និងរួមគ្នាលើកវិធានការបង្ការ ទប់ស្កាត់ ដោះស្រាយបញ្ហានានាទាក់ទងនឹងការងារសន្តិសុខបោះឆ្នោត។

អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ក្នុងនាមប្រធានគណៈបញ្ជាការឯកភាពរាជធានី ខេត្ត និងជាប្រធានយន្តការ-រចនាសម្ព័ន្ធសន្តិសុខរាជធានី ខេត្ត ត្រូវធ្វើការផ្សព្វផ្សាយប្រចាំសប្តាហ៍ពីសភាពការណ៍សន្តិសុខក្នុងរាជធានី ខេត្តរបស់ខ្លួន ដល់ភាគីពាក់ព័ន្ធនានា និងសាធារណជន ដើម្បីទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិត អំពីស្ថានភាពសន្តិសុខសណ្តាប់ធ្នាប់ក្នុងរាជធានី ខេត្តនីមួយៗ។

អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវជំរុញឲ្យស្នងការដ្ឋាននគរបាលរាជធានី ខេត្ត រាយការណ៍ឲ្យបានជាប្រចាំថ្ងៃអំពីសភាពការណ៍ ឬសកម្មភាពបទល្មើសផ្សេងៗដែលកើតមានឡើង ជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងអគ្គស្នងការដ្ឋាននគរបាលជាតិ។ ករណីធ្ងន់ធ្ងរ ត្រូវរាយការណ៍ជាបន្ទាន់ជូនថ្នាក់លើតាមឋានានុក្រម ដើម្បីមានវិធានការដោះស្រាយ។

**ខ.ថ្នាក់ក្រុង ស្រុក ខណ្ឌ**

ដោយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ពុំមានអាជ្ញាធរបោះឆ្នោតឡើយ។ ដូចនេះ អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដែលជាប្រធានគណៈបញ្ជាការឯកភាពក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំក្រុមប្រឹក្សាឃុំ សង្កាត់ និងប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ឲ្យផ្តល់កិច្ចសហការជាប្រចាំដល់អាជ្ញាធររៀបចំការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់។

**គ.ថ្នាក់ឃុំ សង្កាត់**

ថ្នាក់ឃុំ សង្កាត់ ជាថ្នាក់ដែលអនុវត្តផ្ទាល់ និងជាទីកន្លែងដែលមានគ្រប់បញ្ហាកើតឡើងជាក់ស្តែង។ ហេតុនេះ អាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងយន្តការ-រចនាសម្ព័ន្ធសន្តិសុខនៅគ្រប់ថ្នាក់ ព្រមទាំងកម្លាំងមានសមត្ថកិច្ចនានាត្រូវប្រមូលផ្តុំជួយគាំទ្រដល់ឃុំ សង្កាត់ឲ្យបានជាប្រចាំ។

វិធានការណែនាំបន្ថែមអំពីសន្តិសុខបោះឆ្នោតក្នុងសេចក្តីណែនាំនេះ ត្រូវបាត់ចែងអនុវត្តនៅថ្នាក់ឃុំ សង្កាត់។ ដោយឡែក ចំពោះការផ្លាស់ប្តូរព័ត៌មាន និងការជួបប្រជុំ ត្រូវរៀបចំពីរ ឬបីដងក្នុងមួយសប្តាហ៍ និងស្របទៅតាមសំណូមពរចាំបាច់នៃសភាពការណ៍សន្តិសុខក្នុងឃុំ សង្កាត់នីមួយៗ។

**៦-អំពីអព្យាក្រឹតភាពក្នុងតួនាទី ភារកិច្ចរបស់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្នុងដំណើរការបោះឆ្នោត**

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ព្រមទាំងក្រមសីលធម៌សម្រាប់ការបោះឆ្នោត បានតម្រូវឲ្យមន្ត្រីរាជការស៊ីវិលគ្រប់លំដាប់ថ្នាក់ ត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និងត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងក្នុងការងារបោះឆ្នោត។ ក្នុងនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិដែលមិនស្ថិតក្នុងក្របខណ្ឌមុខងារសាធារណៈ ក៏ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តមុខងាររបស់ខ្លួនក្នុងដំណើរការបោះឆ្នោតផងដែរ។

ក្នុងដំណើរការរៀបចំការបោះឆ្នោតកន្លងមក ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមសំដែងនូវការកោតសរសើរចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិទូទាំងប្រទេសដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការនានានៃការបោះឆ្នោត។ ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦នេះ ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសូមអំពាវនាវដល់ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិទាំងអស់ សូមបង្កើនកិច្ចសហការជាមួយអាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងមានសុវត្ថិភាពល្អប្រសើរ។

ទន្ទឹមនេះ ដើម្បីបង្កើតឲ្យមានបរិយាកាសជឿទុកចិត្តថ្នែមទៀតក្នុងការរៀបចំការបោះឆ្នោត មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងពេលបំពេញនូវតួនាទីនេះ ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀង ហើយមិនត្រូវបង្ហាញនូវការគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ។

ក្នុងពេលបំពេញតួនាទីរបស់ខ្លួន មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវធ្វើសកម្មភាពណាមួយ ដូចខាងក្រោម៖

ក.មិនត្រូវប្រើប្រាស់ឥទ្ធិពលនៃតួនាទីរបស់ខ្លួនទៅលើអ្នកបោះឆ្នោត ដែលនាំឲ្យបាត់បង់សិទ្ធិសេរីភាពនៃការជ្រើសរើសរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត។

ខ.មិនត្រូវដកហូតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត ទោះក្នុងកាលៈទេសៈណាក៏ដោយ។

គ.មិនត្រូវសួរនាំអ្នកបោះឆ្នោតក្នុងគោលបំណងដើម្បីជះឥទ្ធិពល ឬចង់ដឹងអំពីលទ្ធផលនៃការបោះឆ្នោតជាសម្ងាត់របស់អ្នកបោះឆ្នោតឡើយ។

ឃ.មិនត្រូវជៀតជ្រែកលើសិទ្ធិអ្នកបោះឆ្នោតក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយសេរី ការចូលរួមក្នុងការពិភាក្សាជាសាធារណៈ ការចូលរួមក្នុងសកម្មភាពនយោបាយនានា ឬការទទួលព័ត៌មានដោយពេញលេញអំពីកិច្ចការនយោបាយឡើយ។

ង.មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដើម្បីបំភិតបំភ័យ ឬគំរាមកំហែងចំពោះអ្នកបោះឆ្នោត។

ច.មិនត្រូវប្រើពាក្យសំដីបញ្ឆិតបញ្ឆៀង ឬថ្កោលទោសបុគ្គលណាម្នាក់ដោយសារផលប្រយោជន៍របស់គណបក្សនយោបាយណាមួយ ឬផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវផ្សព្វផ្សាយវិធានការទាំងនេះ ដល់គ្រប់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ហើយត្រូវធ្វើការណែនាំ ត្រួតពិនិត្យ និងត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិទាំងអស់ក្នុងឃុំ សង្កាត់របស់ខ្លួន។

អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវពិនិត្យមើលជាប្រចាំដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរាជធានី ខេត្តរបស់ខ្លួន អំពីការអនុវត្តគោលការណ៍ណែនាំនេះចំពោះភូមិ ស្របតាមអំណាចដែលបានធ្វើប្រតិភូកម្មតាមប្រកាសរបស់ក្រសួងមហាផ្ទៃលេខ១៨៨៤ ប្រក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២។

ទទួលបានសេចក្តីណែនាំរួមនេះ គ្រប់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត និងគណៈកម្មការរៀបចំការបោះឆ្នោតរាជធានី ខេត្ត ត្រូវសហការធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់អង្គភាព ស្ថាប័នពាក់ព័ន្ធ អាជ្ញាធររៀបចំការបោះឆ្នោត មន្ត្រីបោះឆ្នោត មន្ត្រីរាជការ កងកម្លាំងមានសមត្ថកិច្ច គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងសាធារណជនទូទៅក្នុងរាជធានី ខេត្តនីមួយៗ និងត្រូវអនុវត្តសេចក្តីណែនាំនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**សម្តេចក្រឡាហោម ស ខេង** | **ស៊ិក ប៊ុនហុក**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- គ្រប់អង្គភាពចំណុះក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ - កាលប្បវត្តិ